អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

អគ្គនាយកដ្ឋានស្រាវជ្រាវ

នាយកដ្ឋានស្រាវជ្រាវថវិកា

# ព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច

## មាតិកា៖


- កម្ពុជា អនុម័តគម្រោងវិនិយោគថ្មីមានតម្លៃសរុបជាង១១២លានដុល្លារអាមេរិកនៅខែតុលា ឆ្នាំ២០២១
- ការឆ្ពោះទៅរកទេសចរណ៍ឌីជីថលជាមធ្យោបាយនៃការចាប់ផ្តើមវិស័យទេសចរណ៍ឡើងវិញសម្រាប់កម្ពុជា
- វិស័យសេវាកម្មកម្ពុជា នឹងកើនយឺតនៅឆ្នាំ ២០២២
- តើនៅឆ្នាំ២០២២ ការវិនិយោគវិស័យអចលនទ្រព្យស្ទុះងើបកម្រិតណា?
- ឱនភាពពាណិជ្ជកម្មវៀតណាម ធ្លាក់ចុះដល់ ១.៤៥ ប៊ីលានដុល្លារ បន្ទាប់ពីអតិរេកនៅក្នុងខែតុលា
- គម្រោងលើកទឹកចិត្ត និងហិរញ្ញប្បទាន សម្រាប់អាជីវកម្មក្រោមថវិការបស់ប្រទេសម៉ាឡេស៊ីឆ្នាំ ២០២២
- តម្លៃសំបុត្រយន្តហោះទៅមកកម្ពុជា-ចិន ហក់ឡើងខ្ពស់រហូតដល់ ៥ពាន់ ទៅជាង១ម៉ឺនដុល្លារ
- ធនាគារកណ្តាលនៃសហរដ្ឋអាមេរិក បានបង្ហាញរបាយការណ៍អំពីការព្រួយបារម្ភរបស់វិនិយោគិនចំពោះ អតិផរណាកម្រិតខ្ពស់ក្នុងពេលមាន ការរីករាលដាលនៃជំងឺកូវីដ-១៩
- តម្លៃប្រេងធ្លាក់ចុះបន្ទាប់ពីការកើនឡើង តម្រូវការសម្រាប់ទស្សនវិស័យសេដ្ឋកិច្ចពិភពលោក
- មូលហេតុ តម្លៃស្បៀងអាហារសកលបន្តហក់ឡើងខ្ពស់៣ខែជាប់ៗគ្នានៅឆ្នាំនេះ
- ជប៉ុនគ្រោងចែកប្រាក់ ៨៨០ដុល្លារ ឱ្យពលរដ្ឋចាប់ពីអាយុ១៨ឆ្នាំចុះ ដើម្បីជំរុញកំណើនសេដ្ឋកិច្ច
- ការនាំចេញរបស់ចិននៅតែរក្សាភាពធន់ទោះ ស្ថិតក្នុងវិបត្តិខ្វះខាតថាមពល



ពិនិត្យ និងកែសម្រួលដោយ

- សួន ពុធថាវី អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- គឹម សុចិត្រា អគ្គនាយករង នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- ណុប ចាន់ធី ប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា
- ម៉ែន ខែមរៈ អនុប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា



រៀបរៀងដោយនាយកដ្ឋានស្រាវជ្រាវថវិកា សប្តាហ៍ទី៣ ខែវិច្ឆិកា ឆ្នាំ២០២១ លេខ ៖ ៩៣

# ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

## កម្ពុជា អនុម័តគម្រោងវិនិយោគថ្មីមានតម្លៃសរុបជាង ១១២លានដុល្លារអាមេរិក នៅក្នុងខែតុលា ឆ្នាំ២០២១



*ប្រភព៖ Khmer Times ២០២១*

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) បានអនុម័តគម្រោងវិនិយោគថ្មីចំនួន ១២ ស្មើនឹងទំហំទឹកប្រាក់ ១១២លានដុល្លារអាមេរិក នៅក្នុងខែតុលា ឆ្នាំ២០២១។ ទន្ទឹមនឹងនេះ CDC ក៏បានអនុម័តគម្រោងថ្មីមួយទៀតដល់ក្រុមហ៊ុន ADVANT TRAVEL GOODS (CAMBODIA) CO.,LTD ជាមួយនឹងទុនវិនិយោគចំនួន ៤,៣លានដុល្លារអាមេរិក ដើម្បីបង្កើតរោងចក្រផលិតវ៉ាលី និងរទេះរុញគ្រប់ប្រភេទ ដែលមានទីតាំងស្ថិតនៅភូមិស្លា ឃុំវ៉ាលីស ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ និងអាចបង្កើតការងារបានចំនួន ៣៩៧កន្លែង។

ទោះបីជា កម្ពុជាបាន និងទទួលរងការការញាំញីដោយជំងឺរាតត្បាតកូវីដ-១៩ ក្តី CDC បានអនុម័តគម្រោងវិនិយោគថ្មីៗជាបន្តបន្ទាប់។ នេះសបញ្ជាក់ឱ្យឃើញថា វិបត្តិកូវីដ-១៩ មិនបានបង្អាក់លំហូរនៃការវិនិយោគទៅក្នុងគម្រោងអភិវឌ្ឍន៍ថ្មីៗរបស់អ្នកវិនិយោគជាតិ និងអន្តរជាតិនៅកម្ពុជាឡើយ។

គិតចាប់ពីខែមករា ដល់ខែកញ្ញា ឆ្នាំ២០២១ CDC បានអនុម័តគម្រោងវិនិយោគសរុបចំនួន ១៣៤ ស្មើនឹងទំហំទឹកប្រាក់សរុបចំនួន ៣,៣ប៊ីលានដុល្លារអាមេរិក។ គម្រោងទាំងនោះ ផ្តោតលើវិស័យដូចជា៖ រោងចក្រឧស្សាហកម្ម កសិកម្ម កសិឧស្សាហកម្ម ទេសចរណ៍ និងហេដ្ឋារចនាសម្ព័ន្ធ និងអាចបង្កើតការងារបានចំនួន ៨៥ ៥៧២កន្លែង សម្រាប់ប្រជាពលរដ្ឋកម្ពុជា៕

*ដោយ ស៊ិន សុភារ៉ា*

*ប្រភព៖ Khmer Times ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០២១*

## ការឆ្ពោះទៅរកទេសចរណ៍ឌីជីថល គឺជាមធ្យោបាយនៃការចាប់ផ្តើមវិស័យទេសចរណ៍ឡើងវិញសម្រាប់កម្ពុជា



*ប្រភព៖ Khmer Times ២០២១*

ក្រសួងទេសចរណ៍ កំពុងពិចារណានូវមធ្យោបាយដើម្បីជំរុញការងើបឡើងវិញនៃវិស័យទេសចរណ៍ និងធានាថាភ្ញៀវទេសចរនឹងអាចស្វែងរកបទពិសោធន៍បានយ៉ាងងាយស្រួល និងឆាប់រហ័សក្នុងការរៀបចំការធ្វើដំណើរដោយមិនមានបញ្ហា នៅពេលពួកគេមកដល់ប្រទេសកម្ពុជា ហើយអ្វីដែលសំខាន់នោះគឺមានសុវត្ថិភាព។ ចម្លើយនោះគឺការឆ្ពោះទៅរកទេសចរណ៍ឌីជីថល នេះបើយោងតាមសម្តីរបស់ឯកឧត្តម អាំង សុវណ្ណរ័ត្ន អគ្គ

នាយករងនៃអគ្គនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ និងសហប្រតិបត្តិការអន្តរជាតិនៃក្រសួងទេសចរណ៍កម្ពុជា។ ឯកឧត្តម បញ្ជាក់ថា ការសម្របខ្លួន និងទទួលស្គាល់នូវបច្ចេកវិទ្យាឌីជីថល គឺមានសារៈសំខាន់ដោយសារបច្ចេកវិទ្យាឌីជីថលមានភាពទូលំទូលាយ និងជានិន្នាការអន្តរជាតិ ដែលកំពុងតែកើតឡើងជាមួយនឹងបដិវត្តន៍ឧស្សាហកម្មទី៤ នាពេលខាងមុខ។ វិស័យបច្ចេកវិទ្យាឌីជីថល បាននិងកំពុងជះឥទ្ធិពលលើវិស័យសេដ្ឋកិច្ច-សង្គម និងវិស័យនានានៅក្នុងប្រទេសកម្ពុជា រួមទាំងវិស័យទេសចរណ៍ផងដែរ។ ដើម្បីឆ្លើយតបទាន់វេលានៃទេសចរណ៍ឌីជីថល ដែលសំដៅដល់ការអភិវឌ្ឍន៍ទេសចរណ៍ឆ្លាតវៃ ការគិតគូរដល់ការអភិវឌ្ឍធនធានមនុស្សគឺជារឿងចម្បងព្រោះថាបច្ចេកវិទ្យា និងមនុស្សត្រូវតែដើរទន្ទឹមគ្នា។ ប្រសិនបើកម្ពុជា ចង់ទទួលបាននូវអត្ថប្រយោជន៍ពីបច្ចេកវិទ្យា ដែលកំពុងរីកចម្រើននេះ កម្ពុជាត្រូវតែប្រាកដថាកម្លាំងពលកម្មក្នុងឧស្សាហកម្មទេសចរណ៍មានសមត្ថភាពគ្រប់គ្រាន់ក្នុងការប្រើប្រាស់បច្ចេកវិទ្យាថ្មីដើម្បីបង្កើនផលិតភាព កែលម្អសេវាកម្ម និងគុណភាពនៃផលិតផលរបស់ពួកគេ។

ឯកឧត្តម ក៏បានឱ្យដឹងទៀតថាក្រសួងទេសចរណ៍នឹងបើកកម្មវិធីបណ្តុះបណ្តាលអក្ខរកម្មឌីជីថលសម្រាប់វិស័យទេសចរណ៍នៅក្នុងសប្តាហ៍នេះ ដើម្បីជួយដល់ឧស្សាហកម្មទេសចរណ៍ងើបឡើងវិញនៅលើវិថីបច្ចេកវិទ្យាមួយនេះ។

សូមបញ្ជាក់ដែរថា ប្រទេសកម្ពុជា បាននិងកំពុងធ្វើការជាមួយដៃគូអាស៊ានក្នុងការសម្របខ្លួនទៅនឹងបច្ចេកវិទ្យាចុងក្រោយបង្អស់នេះ ដើម្បីជួយដល់បុគ្គលិក-កម្មករនៅក្នុងឧស្សាហកម្មទេសចរណ៍អាចដើរទាន់ការវិវត្តន៍ និងចេះពីរបៀបប្រើប្រាស់ និងប្រើប្រាស់ឱ្យមានលក្ខណៈឯកភាព និងស្តង់ដារនៅក្នុងតំបន់។ មេដឹកនាំនៃប្រទេសសមាជិកអាស៊ានទាំង១០ បានចេញសេចក្តីប្រកាសរួមស្តីពីទេសចរណ៍ឌីជីថល នៅក្នុងកិច្ចប្រជុំកំពូលអាស៊ានកាលពីខែវិច្ឆិកា ឆ្នាំ២០២០ កន្លងមក៕

*ដោយ ស៊ិន សុភាព៉*

*ប្រភព៖ Khmer Times ចុះថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០២១*

## វិស័យសេវាកម្មកម្ពុជា នឹងកើនយឺតនៅឆ្នាំ ២០២២



*ដោយ ខេមបូណូមីស (ខេត្តកោះកុង)*

វិស័យសំខាន់ៗចំនួន៣ ជាក្បាលម៉ាស៊ីនជំរុញសេដ្ឋកិច្ចកម្ពុជានៅឆ្នាំ២០២២ ឱ្យមានកំណើនក្នុងអត្រា៤,៨% រួមមាន វិស័យឧស្សាហកម្ម វិស័យកសិកម្ម និងវិស័យសេវាកម្ម។ វិស័យសេវាកម្មនៅឆ្នាំ២០២២ នឹងងើបឡើងវិញយឺត ដោយសារអនុវិស័យសណ្ឋាគារ និងភោជនីយដ្ឋាន នឹងងើបឡើងស្ថិតក្នុងកម្រិតទាប ទាំងទំហំ និងអត្រាកំណើន ព្រោះកំណើនយឺតនៃភ្ញៀវទេសចរអន្តរជាតិ។ ចំពោះទេសចរជាតិ នឹងងើបឡើងក្នុងសន្ទុះលឿន ព្រោះការរាតត្បាតកូវីដ-១៩ ក្នុងសហគមន៍បានស្រាកស្រាន្ត និងគ្រប់គ្រងស្ថានការណ៍បានឡើងវិញ។

ប្រធានសមាគមសណ្ឋាគារកម្ពុជា បានយល់ឃើញថា បើទោះបីភ្ញៀវទេសចរផ្ទៃក្នុង ចាប់ផ្តើមងើបឡើងវិញបណ្តើរៗ ប៉ុន្តែរហូតមកដល់ពេលនេះ វិស័យសណ្ឋាគារហាក់មិនទាន់មានការកម្រើកឡើងវិញ នៅឡើយទេ ព្រោះមិនទាន់មានវត្តមានរបស់ភ្ញៀវអន្តរជាតិ។

ប្រមុខរាជរដ្ឋាភិបាល ក៏បានលើកឡើងដែរ ថាវិស័យសេវាកម្ម បានរងផលប៉ះពាល់ធ្ងន់ធ្ងរ ដោយសារការរាតត្បាតកូវីដ-១៩។ ការបើកប្រទេសឡើងវិញលើគ្រប់វិស័យ នឹងចូលរួមស្តារវិស័យសេវាកម្ម ក៏ដូចជា ស្តារសេដ្ឋកិច្ចជាតិ ឡើងវិញ។

កំណើនសេដ្ឋកិច្ចកម្ពុជានាឆ្នាំ២០២២ តាមការព្យាករណ៍គឺ វិស័យឧស្សាហកម្ម នឹងសម្រេចបានកំណើន ៧,៧%ពីកំណើន៥,៧% ក្នុងឆ្នាំ២០២១, វិស័យសេវាកម្ម នឹងសម្រេចបានកំណើន៤,១% ពីកំណើន ០,៣% ក្នុងឆ្នាំ២០២១ និងវិស័យកសិកម្មវិញ នឹងសម្រេចបានកំណើនក្នុងអត្រាទាប១,១% បើធៀបនឹងកំណើន១,៤% ក្នុងឆ្នាំ២០២១៕ *ដោយ ម៉ែន ខេមរៈ*

*ប្រភព៖ខេមបូណូមីស ចេញផ្សាយថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២១។*

## តើនៅឆ្នាំ២០២២ ការវិនិយោគវិស័យអចលនទ្រព្យស្ទុះងើបកម្រិតណា?



*រូបភាព៖ ហេង ការម្យ*

ចរន្តវិនិយោគលើវិស័យអចលនទ្រព្យ បានចាប់ផ្តើមកំរើកឡើងវិញបណ្តើរៗហើយ ក្រោយរាជរដ្ឋាភិបាលកម្ពុជា សម្រេចបើកសកម្មភាពសង្គម និងសេដ្ឋកិច្ចលើគ្រប់វិស័យឡើងវិញ កាលពីថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២១។ ទោះបីក្នុងអំឡុងនៃវិបត្តិកូវីដ-១៩ ចំនួនអ្នកទិញអចលនទ្រព្យមានការថយចុះ តែតម្លៃអចលនទ្រព្យមិនមានការប្រែប្រួល គួរឲ្យកត់សម្គាល់នោះទេ។

ប្រធានសមាគមអ្នកវាយតម្លៃ និងភ្នាក់ងារអចលនវត្ថុកម្ពុជាបានព្យាករណ៍ថា ការវិនិយោគលើវិស័យអចលនទ្រព្យនៅកម្ពុជា នឹងមានកំណើនចន្លោះពី ៣០%ទៅ ៤០%នៅដើមឆ្នាំ២០២២ ខាងមុខ ព្រោះវិនិយោគិនជាតិ និងអន្តរជាតិ(ចិន ជប៉ុន និងសហរដ្ឋអាមេរិក) កំពុងសំឡឹងមើលឱកាសវិនិយោគលើវិស័យនេះ នៅតាមបណ្តាខេត្តនានា ជាពិសេសនៅតំបន់ជាយក្រុងតែម្តង។ តម្លៃអចលនទ្រព្យកម្ពុជានៅមានកម្រិតទាបនៅឡើយបើធៀបនឹងតម្លៃអចលនទ្រព្យជាមួយប្រទេសក្នុងតំបនអាស៊ាន ដែលកត្តានេះ ធ្វើឱ្យកម្ពុជាមានឱកាសខ្ពស់ក្នុងការទាក់ទាញវិនិយោគិនបរទេស។ វិស័យអចលនទ្រព្យនៅកម្ពុជា នៅតែអាចផ្តល់អត្ថប្រយោជន៍និងប្រាក់ចំណេញខ្ពស់នៅក្នុងរយៈពេល១ឆ្នាំទៅ២ឆ្នាំខាងមុខ ដូច្នេះនៅរយៈពេល៣ឆ្នាំទៅ៥ឆ្នាំខាងមុខ វិនិយោគិនកម្ពុជានឹងអាចឈានជើងទៅវិនិយោគលើវិស័យអចលនទ្រព្យនៅតាមប្រទេសនានានៅអាស៊ាន និងក្នុងតំបន់៕ *ដោយ ម៉ែន ខេមរៈ*

*ប្រភព៖ខេមបូណូមីស ចេញផ្សាយថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២១។*

## ការនាំចេញរបស់កម្ពុជាទៅថៃធ្លាក់ចុះ២៨% ខណៈនាំចូលពីថៃកើន ១៤% នៅ៩ខែឆ្នាំនេះ




*ដោយ ខេមបូណូមីស*

នៅ៩ខែក្នុងឆ្នាំ២០២១ការនាំចេញរបស់កម្ពុជាកាន់ទៅប្រទេសថៃ ធ្លាក់ចុះរហូតដល់២៨% បើធៀបនឹង

រយៈពេលដូចគ្នាកាលពីឆ្នាំមុខ។ ប៉ុន្តែការនាំចូលទំនិញពីថៃមកកម្ពុជានៅតែរក្សាបានកំណើន១៤%។ ទំហំពាណិជ្ជកម្មទ្វេភាគីរវាងប្រទេសទាំងពីរនៅ៩ខែក្នុងឆ្នាំនេះ កើនឡើង១៨% បើធៀបនឹង៩ខែកាលពីឆ្នាំ២០២០។ ទិន្នន័យពីនាយកដ្ឋានគយថៃបានបង្ហាញឱ្យឃើញថា ការនាំចេញទំនិញពីកម្ពុជា សម្រេចបាន៦៨៧លានដុល្លារបើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុខ ដែលមានទឹកប្រាក់ចំនួន៩៥៨លានដុល្លារ។ ប៉ុន្តែបើយើងមើលទៅលើតួលេខនាំចូលពីថៃមកកម្ពុជាវិញ គឺនៅតែបង្ហាញសញ្ញាវិជ្ជមាន ជាមួយទំហំទឹកប្រាក់ជាង៥ពាន់២រយលានដុល្លារកើនឡើង១៤% បើធៀបនឹង៩ខែកាលពីឆ្នាំ២០២០ ដែលមានតែជាង៤ពាន់៦រយលានដុល្លារ តែប៉ុណ្ណោះ។ មុខទំនិញដែលកម្ពុជានាំចេញទៅថៃ រួមមានផលិតផលវាយនភណ្ឌ កសិផលត្បូងថ្មមានតម្លៃ វត្ថុធាតុដើម និងប្រភេទពាក់កណ្តាលសម្រេច ខណៈកម្ពុជានាំចូលទំនិញពីថៃវិញរួមមានថាមពល ត្រី សាច់ រថយន្ត ជីសរីរាង្គ ស៊ីម៉ង់ត៏ គ្រឿងឧបភោគ-បរិភោគ គ្រឿងសំអាង និងសម្ភារៈសំណង់៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណ្ឌមីស ចេញផ្សាយថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២១។*

## តម្លៃសំបុត្រយន្តហោះទៅមកកម្ពុជា-ចិន ហក់ឡើងខ្ពស់ ហួតដល់ ៥ពាន់ ទៅជាង១ម៉ឺនដុល្លារ




*ដោយ ខេមបូណ្ឌមីស(ព្រលានយន្តហោះអន្តរជាតិភ្នំពេញ)*

ក្រោយពេលមានការប្រកាសពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា ឱ្យមានការបើកប្រទេសឡើងវិញ និងការត្រៀមខ្លួនទទួលភ្ញៀវទេសចរចាក់វ៉ាក់សាំងរួច ចាប់ពីចុងខែវិច្ឆិកា តទៅនោះ គេសង្កេតឃើញ ក្រុមហ៊ុនអាកាសចរណ៍ជាច្រើន ចាប់ផ្តើមស្ទុះស្ទារៀបចំខ្លួនក្នុងការបើកប្រតិបត្តិការដឹកភ្ញៀវទេសចរអន្តរជាតិឡើងវិញ។ ប៉ុន្តែអ្វីដែលគួរឱ្យចាប់អារម្មណ៍នោះ គឺតម្លៃសំបុត្រយន្តហោះប្រទេសកម្ពុជា និងចិន កំពុងឡើងថ្លៃខ្លាំង ខណៈដែលថ្លៃសំបុត្រយន្តហោះទៅកាន់ទិសដៅប្រទេសផ្សេងៗទៀត នឹងឡើងថ្លៃតិចតួច។បច្ចុប្បន្នតម្លៃសំបុត្រយន្តហោះកម្ពុជា-ចិន តែ១ជើង ចេញពីកម្ពុជាទៅចិនឬពីចិនមកកម្ពុជា មានតម្លៃរហូត ៥ពាន់-១ម៉ឺនដុល្លារឯណោះ ដែលកាលពីមុន ការធ្វើដំណើរ១ជើងតម្លៃសំបុត្រ ត្រឹមតែ៤០០ ទៅ៥០០ដុល្លារប៉ុណ្ណោះ ឬអាចក្រោមនេះក៏មានដែរ។

កត្តាដែលធ្វើឱ្យតម្លៃសំបុត្រយន្តហោះរវាងកម្ពុជា-ចិនឡើងខ្ពស់បែបនេះគឺ កាលពីថ្ងៃទី២ ខែវិច្ឆិកា ទីក្រុងប៉េកាំង បានប្រកាសលុបចោលជើងហោះហើរប្រមាណ៥០% ដើម្បីទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ ក្រោយប្រទេសនេះមានករណីឆ្លងកូវីដ-១៩ សារជាថ្មី។ សព្វថ្ងៃ មានក្រុមហ៊ុនអាកាសចរណ៍មិនដល់១០ក្រុម

ហ៊ុនទេ ដែលកំពុងដំណើរការ ខណៈកាលពីមុនវិបត្តិកូវីដ-១៩ មានប្រមាណ ៤០ក្រុមហ៊ុន បានដំណើរការ។ ការលុបចោលជើងហោះហើរ គួបផ្សំនឹងវិធានការរឹតត្បិតនៃអ្នកដំណើរចេញ-ចូលប្រទេសចិន បានជះឥទ្ធិពលដល់ការធ្វើដំណើរនៃអ្នកដំណើរចិនចូលមកកម្ពុជា។

អ្នកនាំពាក្យរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល បង្ហាញពីការព្រួយបារម្ភអំពីតម្លៃសំបុត្រយន្តហោះឡើងថ្លៃខ្លាំងរវាងកម្ពុជា-ចិន អាចជាការរាំងស្ទះដល់ផែនការទាក់ទាញទេសចរចិន នាពេលខាងមុខ ព្រោះរាជរដ្ឋាភិបាលកម្ពុជា បានកំណត់ទេសចរចិន គឺជាអាទិភាពក្នុងផែនការ។ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណ្ឌមីស ចេញផ្សាយថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២១។*

## តម្លៃជ្រូករស់ក្នុងស្រុកចាប់ផ្តើមប្រសើរឡើងវិញបន្តិចក្រោយការនាំចូលជ្រូកពីខាងក្រៅបានថយចុះ



*ដោយ ខេមបូណ្ឌមីស(កសិដ្ឋានចិញ្ចឹមជ្រូករបស់កសិករក្នុងស្រុកមួយកន្លែង)*

បច្ចុប្បន្ន តម្លៃជ្រូករស់នៅកម្ពុជាបានប្រសើរឡើងវិញបន្តិច បើធៀបនឹងអំឡុងពិធីបុណ្យភ្ជុំបិណ្ឌកន្លងមក ដែលអាចលក់បានក្នុងតម្លៃ ១ម៉ឺនរៀល ក្នុងមួយគីឡូក្រាមខណៈកាលពីអំឡុងពិធីបុណ្យភ្ជុំបិណ្ឌជ្រូករស់ក្នុងស្រុកអាចលក់បានត្រឹម៩ពាន់រៀលមួយគីឡូក្រាម។ សមាគមអ្នកចិញ្ចឹមសត្វនៅកម្ពុជាអះអាងថា ស្ថានភាពទីផ្សារ និងការចិញ្ចឹមជ្រូក ចាប់ផ្តើមល្អឡើងវិញជាបណ្តើរៗហើយ ដោយសារតម្លៃជ្រូករស់ក្នុងស្រុកកាន់តែប្រសើរ។ ការប្រែប្រួលនៃតម្លៃជ្រូករស់ក្នុងស្រុក ដោយសារតែតម្លៃជ្រូករស់ នៅប្រទេសជិតខាង ដូចជា ប្រទេសថៃ និងវៀតណាមជាដើម ឡើងថ្លៃ ដូច្នេះ ឈ្មួញបានផ្អាកនាំចូលមកកម្ពុជា។ ម្យ៉ាងទៀត ស្ថាប័នពាក់ព័ន្ធកាន់តែរឹតបន្តឹងច្បាប់នាំចូលជ្រូករស់ និងជ្រូករស់ខុសច្បាប់ ដែលធ្វើឱ្យតម្លៃជ្រូករស់ក្នុងស្រុកចាប់ផ្តើមប្រសើរឡើងវិញ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានកាត់បន្ថយការនាំចូលជ្រូករស់ពីបរទេសមកនៅត្រឹម ៧០០ក្បាល ទៅ៨០០ក្បាល ក្នុងមួយថ្ងៃ ហើយចុងក្រោយនេះ បានបន្តកាត់មកនៅត្រឹម៣០០ក្បាល ប៉ុណ្ណោះក្នុងមួយថ្ងៃ។ បច្ចុប្បន្ន កម្ពុជា មានតម្រូវការជ្រូករស់ប្រមាណ ៨ពាន់ក្បាល ក្នុងមួយថ្ងៃ នៅលើទីផ្សារក្នុងស្រុក ដែលកម្ពុជា មានលទ្ធភាពក្នុងការផ្គត់ផ្គង់ជ្រូក។ ដូច្នេះ កម្ពុជា មិនចាំបាច់បន្តនាំចូលជ្រូករស់ពីបរទេសបន្តទៀតនោះទេ។ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណ្ឌមីស ចេញផ្សាយថ្ងៃទី០៨ខែវិច្ឆិកា ឆ្នាំ២០២១។*

## ការនាំចេញស្រូវសម្រេចបានទឹកប្រាក់ លើសពីការនាំចេញអង្ករជិត២ដង នៅ១០ខែឆ្នាំ២០២១



*ដោយ ខេមបូណ្ឌមីស*

ទឹកប្រាក់នាំចេញអង្ករ និងស្រូវរបស់កម្ពុជាបូកបញ្ចូលគ្នានៅ១០ខែឆ្នាំ២០២១នេះ សម្រេចបានដល់ទៅ ជិត ៩៦០លានដុល្លារអាមេរិក ដោយក្នុងនោះ ទឹកប្រាក់ដែលបានមកពីការនាំចេញស្រូវ មានដល់ប្រមាណ ៦៣៣លានដុល្លារ លើសការនាំចេញអង្ករដល់ទៅជិត ២ដង។ បើមើលទៅលើបរិមាណនាំចេញវិញ ឃើញថាការនាំចេញស្រូវបានជាង២លាន៦សែនតោន កើន

ជាង៨៦% រីឯការនាំចេញអង្ករវិញមានជាង ៤៦ម៉ឺនតោន ថយចុះជា១៤%។ ប្រទេសចិន គឺជាទីផ្សារធំជាងគេ រីឯវៀតណាម ជាទីផ្សារនាំចេញស្រូវ។

ទីផ្សារនាំចេញអង្ករចម្បងរបស់កម្ពុជាមាន៥ រួមមានប្រទេសចិន ៧៩% , តំបន់ស្វយ័តហុងកុង ម៉ាកាវ ជាង ៤៩%, បារាំង១១%, ហ្គាប៊ុង ជិត៨%,ម៉ាឡេស៊ី ជាង ៦% និងហូឡង់ ជិត៤%។ កត្តាដែលជំរុញឱ្យការនាំចេញអង្កររបស់កម្ពុជាទៅទីផ្សារចិនកាន់តែច្រើន ព្រោះតែ កម្ពុជា-ចិន ក៏មានការចុះអនុស្សរណៈនៃការនាំចេញអង្ករ ពីកម្ពុជាចំនួន ៤០ម៉ឺនតោន គួបផ្សំនឹងអង្ករកម្ពុជាមានគុណភាពល្អផងដែរ។

យ៉ាងណាក៏ដោយ ការនាំចេញអង្ករកម្ពុជានាឆ្នាំនេះ បានជួបបញ្ហាខ្លះៗអំឡុងវិបត្តិកូវីដ-១៩ បានថយចុះប្រមាណ១៤% បើធៀបនឹងរយៈពេល១០ខែ កាលពីឆ្នាំ២០២០ ព្រោះកម្ពុជា ខ្វះទូកុងតឺន័រ និងតម្លៃដឹកជញ្ជូនខ្ពស់។ បើសិនមិនមានបញ្ហាទាំងនេះទេ ការនាំចេញអង្ករកម្ពុជា នឹងកើនទ្វេដង។

យោងតាមរបាយការណ៍របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រយៈពេល ១០ខែ ឆ្នាំ២០២១ កម្ពុជាទទួលបានចំណូលជាង ៤ពាន់លានដុល្លារពីការនាំចេញផលិតផលកសិកម្ម ខណៈដែលវិស័យកសិកម្មបានដើរតួនាទីយ៉ាងសំខាន់ នៅក្នុងការជួយទ្រទ្រង់កំណើនសេដ្ឋកិច្ចនៅក្នុងអំឡុងវិបត្តិកូវីដ១៩នេះ៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូឌាមីសចេញផ្សាយថ្ងៃទី០៨ខែវិច្ឆិកា ឆ្នាំ២០២១។*

## គារាងប្រចាំសប្តាហ៍

### រូបភាពទី១៖ កំណើននៃអតិផរណា និងអត្រាប្តូរប្រាក់ ក្នុងត្រីមាសទី២ ឆ្នាំ២០២១

យោងតាមព្រឹត្តិបត្រស្ថិតសេដ្ឋកិច្ច និងហិរញ្ញវត្ថុប្រចាំ ត្រីមាសទី២ ឆ្នាំ២០២១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃកម្ពុជា ដែលមានដូចជា អតិផរណា និងអត្រាប្តូរប្រាក់បានកើនឡើង គិតត្រឹមត្រីមាសទី២ ឆ្នាំ២០២១។ អតិផរណាមធ្យមប្រចាំត្រីមាសទី២ ឆ្នាំ២០២១ មានអត្រា ២,៨% បើធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០២០ ក្នុងនោះដែរ ក្រុមអាហារ និងភេសជ្ជៈមិនមានជាតិស្រវឹងបានកើនឡើង ២,៤%។ ទន្ទឹមនឹងនេះ អត្រាប្តូរប្រាក់ជាមធ្យម ៤ ០៦៣,២ រៀល/ ដុល្លារអាមេរិក បានធ្លាក់ចុះ០,៦% បើធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០២០៕

*ដោយ ឈន ហាំ*

**រូបភាពទី១៖ ស្ថានភាពអតិផរណា និងអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិក(មធ្យមប្រចាំត្រីមាស)**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

*ប្រភព៖ ព្រឹត្តិបត្រស្ថិតសេដ្ឋកិច្ច និងហិរញ្ញវត្ថុប្រចាំមាសទី២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២១*

### រូបភាពទី២៖កំណើន នៃស្ថានភាពហិរញ្ញវត្ថុសាធារណៈ

យោងតាមព្រឹត្តិបត្រស្ថិតសេដ្ឋកិច្ច និងហិរញ្ញវត្ថុប្រចាំត្រីមាសទី២ ឆ្នាំ២០២១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជាដែលមានដូចជា ស្ថានភាពហិរញ្ញវត្ថុសាធារណៈបានកើនឡើង ក្នុងត្រីមាសទី២ ឆ្នាំ២០២១។

## រូបភាពទី២៖ ស្ថានភាពហិរញ្ញវត្ថុសាធារណៈ(គិតជាប៊ីលានរៀល)




ប្រភព៖ អគ្គនាយកដ្ឋានគោលនយោបាយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គិតត្រឹមក្នុងត្រីមាសទី២ ឆ្នាំ២០២១នេះ ការប្រមូលចំណូលក្នុងប្រទេសសរុបអនុវត្ត បានចំនួនប្រហែល ៥ ៤៤៩ ប៊ីលានរៀល ស្មើនឹង ២៨% នៃច្បាប់ថវិកាប្រចាំឆ្នាំ បានធ្លាក់ចុះ២,៥% ។ ក្នុងនោះ ចំណូលចរន្តសរុបប្រហែល ៥ ៤៤០ ប៊ីលានរៀល បានថយចុះ១,៨% បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២០។ ចំណែកឯចំណាយសរុបអនុវត្តបាន ៥ ២១០ ប៊ីលានរៀន ស្មើនឹង ១៨% នៃច្បាប់ថវិកាប្រចាំឆ្នាំបានធ្លាក់ចុះជិត ១៨% បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

សរុបជារួម គិតត្រឹមត្រីមាសទី២ ឆ្នាំ២០២១នេះ ការអនុវត្តថវិកា មានអតិរេកចរន្តចំនួនប្រមាណ ១ ៧៥៤ ប៊ីលានរៀល ស្មើនឹង៣២% បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២០។ ***ដោយ ឈន ហ៊ា***

*ប្រភព៖ ព្រឹត្តិបត្រស្ថិតសេដ្ឋកិច្ច និងហិរញ្ញវត្ថុប្រចាំត្រីមាសទី២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២១*

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### ពាណិជ្ជកម្មអន្តរជាតិរបស់ថៃនៅក្នុងខែសីហា ឆ្នាំ២០២១ (គិតជាពាន់លានដុល្លារ)

ការនាំចេញទំនិញសរុបរបស់ប្រទេសថៃមានចំនួន ២១,៩៨ ពាន់លានដុល្លារ នៅក្នុងខែសីហា ឆ្នាំ២០២១ ធៀបទៅនឹងខែរយៈពេលដូចគ្នាកាលពីឆ្នាំមុន បានកើនឡើង៨,៩៣%។ កំណើននៃការនាំចេញនោះ រួមមានកំណើនផលិតផលកសិកម្ម និងផលិតផលកសិឧស្សាហកម្មបានរួមចំណែក ២៣,៦ ពាន់លានដុល្លារ ធៀបទៅនឹងខែរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ រីឯកំណើននៃការនាំចេញផលិតផលឧស្សាហកម្មបានរួមចំណែក ៣,៣% ធៀបទៅនឹងខែរយៈពេលដូចគ្នាកាលពីឆ្នាំមុន។

គោលដៅទីផ្សារ៖

- ការនាំចេញទំនិញទាំងនោះទៅកាន់ទីផ្សារចំបងបានកើនឡើង១៨,២% ក្នុងនោះទៅអាមេរិក ចិន ជប៉ុន សហភាពអឺរ៉ុប (២៧) និងអាស៊ាន (៥) រួមចំណែក ១៦,២%, ៣២,៣%, ១០,០%, ១៦,១% និង ២៦,៩% រៀងគ្នា។
- ការនាំចេញទៅកាន់ទីផ្សារបន្ទាប់បន្សំបានកើនឡើង ១៨,៤% ដែលការនាំចេញទៅកាន់អាស៊ីខាងត្បូង មជ្ឈិមបូព៌ា អាហ្វ្រិក អាមេរិកឡាទីន និងរុស្ស៊ី រួមចំណែក ៥៤,៥%, ៣១,៩%, ២៧,៥% និង ៥០,៨% រៀងគ្នា។
- ការនាំចេញទៅកាន់ទីផ្សារផ្សេងទៀតបានធ្លាក់ចុះ ៩០,១% ដោយសារការនាំចេញទៅកាន់ប្រទេសស្វីស មានការថយចុះ៩៤%។

គួបញ្ជាក់ផងដែរ ប្រទេសថៃមានឱនភាពពាណិជ្ជកម្ម ១,២២ ពាន់លានដុល្លារអាមេរិក នៅក្នុងខែសីហា ឆ្នាំ ២០២១។ *ដោយ ជឹម ប៊ុនធឿន*

| | ទំហំជួញដូរ |
|---|---|
| ការនាំចូល | ២១,៩៨ |
| ការនាំចេញ | ២៣,១៩ |
| តុល្យភាពពាណិជ្ជកម្ម | -១,២២ |

*ប្រភព៖ http://www.tpso.moc.go.th*

## ឱនភាពពាណិជ្ជកម្មវៀតណាម ធ្លាក់ចុះដល់ ១.៤៥ ប៊ីលានដុល្លារ បន្ទាប់ពីអតិរេកនៅក្នុងខែតុលា



*ប្រភព៖ VnExpress, រូបភាព៖ Quynh Tran*

អតិរេកពាណិជ្ជកម្មវៀតណាម ចំនួន១១ប៊ីលានដុល្លារ ក្នុងខែតុលា បានធ្វើឱ្យឱនភាពសម្រាប់ឆ្នាំនេះធ្លាក់ចុះដល់ ១.៤៥ ប៊ីលានដុល្លារ យោងតាមក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្មវៀតណាម។

ក្នុងរយៈពេល ១០ខែដំបូង ការនាំចេញ បានកើនឡើងជិត ១៧% ធៀបនឹងឆ្នាំមុន ដល់ជាង ២៦៧.៩ ប៊ីលានដុល្លារ ដោយសហគ្រាសបរទេសមានចំនួន ១៩៨.១៦ ប៊ីលានដុល្លារ។ ការនាំចេញដែក បានកើនឡើង ១៣២% ដល់៩,៦៥ ប៊ីលានដុល្លារ ខណៈដែលការនាំចេញគ្រឿងម៉ាស៊ីន ឧបករណ៍ ឧបករណ៍ និងគ្រឿងបន្លាស់ ទទួលបានជិត ២៩,៦ប៊ីលានដុល្លារ កើនឡើង៤០%។ ចំណែកឯការនាំចូល បានកើនឡើង២៨,២% ដល់ជិត ២៦៩.៤ប៊ីលានដុល្លារ។

សហរដ្ឋអាមេរិក នៅតែជាគោលដៅនាំចេញធំជាងគេរបស់វៀតណាម ជាមួយនឹងការដឹកជញ្ជូនជាង ៧៦ប៊ីលានដុល្លារ កើនឡើងជិត ២២% ប្រចាំឆ្នាំ បន្ទាប់មកចិនមាន៤៤.៧ ប៊ីលានដុល្លារ សហភាពអឺរ៉ុបដែលមានទឹកប្រាក់៣១.៧ ប៊ីលានដុល្លារ អាស៊ាន មាន ២៣.០៣ ប៊ីលានដុល្លារ និងជប៉ុន ១៧.៩ ប៊ីលានដុល្លារ។ ហើយប្រទេសចិន គឺជាអ្នកផ្គត់ផ្គង់ទំនិញដ៏ធំបំផុតរបស់វៀតណាម ដែលមានទឹកប្រាក់ចំនួន៨៩.៤៣ប៊ីលានដុល្លារ បន្ទាប់មកកូរ៉េខាងត្បូងមាន ៤៥.៥២ ប៊ីលានដុល្លារ អាស៊ានមាន ៣៣ ប៊ីលានដុល្លារ ប្រទេសជប៉ុនមាន១៨ ប៊ីលានដុល្លារនិងសហរដ្ឋអាមេរិកមាន១៣ប៊ីលានដុល្លារ។ ទន្ទឹមនឹងនេះ អតិរេកក្នុងរយៈពេល ៤ខែដំបូងនៃឆ្នាំនេះ ប្រែទៅជាឱនភាពចាប់តាំងពីខែឧសភា ប៉ុន្តែវាត្រូវបានគេរំពឹងថានឹងថយចុះបន្ថែមទៀតនៅក្នុងខែខាងមុខនេះ ដោយសារវៀតណាមបានទាញយកកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីបន្ថែមទៀត និងតម្រូវការទំនិញសកលកើនឡើង។ *ដោយ វត្ថា វង្សវឌ្ឍនៈ*

*ប្រភព៖ VNExpress ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២១*

## គម្រោងលើកទឹកចិត្ត និងហិរញ្ញប្បទាន សម្រាប់អាជីវកម្មក្រោមថវិការបស់ប្រទេសម៉ាឡេស៊ីឆ្នាំ ២០២២




*ប្រភព៖ ThailandBusinessNews*

រដ្ឋាភិបាលម៉ាឡេស៊ី បានប្រកាសថវិការដ្ឋដ៏ធំបំផុតរបស់ខ្លួនក្នុងប្រវត្តិសាស្ត្រនៅថ្ងៃទី ២៩ ខែតុលា ឆ្នាំ ២០២១ ដែលមានចំនួនសរុប ៨០.២ប៊ីលានដុល្លារអាមេរិក ខណៈដែលរដ្ឋាភិបាលមានគោលបំណងជំរុញកំណើនសេដ្ឋកិច្ចក្រោយការរីករាលដាល់ជំងឺកូវីដ១៩ នៅឆ្នាំ

២០២២។ ស្របពេលដែលសេដ្ឋកិច្ចរបស់ប្រទេសម៉ាឡេស៊ី បានធ្លាក់ចុះ ៥.៦% ក្នុងឆ្នាំ ២០២០ ដែលជាកម្រិតទាបបំផុតរបស់ម៉ាឡេស៊ី ចាប់តាំងពីការធ្លាក់ចុះ ៧.៤%ក្នុងអំឡុងពេលវិបត្តិហិរញ្ញវត្ថុអាស៊ីឆ្នាំ១៩៩៨។ ថវិកាផ្តល់នូវការលើកទឹកចិត្ត ជំនួយ និងគម្រោងហិរញ្ញប្បទានជាច្រើនសម្រាប់អាជីវកម្ម។ មួយចំនួនក៏ជាផ្នែកបន្ថែមនៃអត្ថប្រយោជន៍ដែលមានក្នុងថវិកាវដ្តឆ្នាំ ២០២១ផងដែរ។ ទាំងនេះរួមបញ្ចូលច្រើនជាង៤.៥ប៊ីលានដុល្លារអាមេរិក ក្នុងការផ្តល់មូលនិធិសម្រាប់សហគ្រាសធុនតូច ខ្នាតតូច និងមធ្យម(MSMEs) និងកម្មវិធីឧបត្ថម្ភធនប្រាក់ឈ្នួល ដើម្បីជួយនិយោជកជួលជនជាតិម៉ាឡេស៊ី។ ជាងនេះទៅទៀត រដ្ឋាភិបាលក៏បានផ្តល់ប្រាក់កម្ចីចំនួន២.៤ប៊ីលានដុល្លារអាមេរិក សម្រាប់ប្រាក់កម្ចី ដែលជួយចំពោះអាជីវកម្ម Bumiputera (អាជីវកម្មដែលគ្រប់គ្រងដោយជនជាតិភាគតិចម៉ាឡេភាគច្រើនរបស់ប្រទេស)។

និយោជក ដែលជួលជនជាតិម៉ាឡេស៊ី ដែលមិនទាន់បានធ្វើការសកម្ម មានសិទ្ធិទទួលបានការលើកទឹកចិត្តក្នុងទម្រង់ជាកម្មវត្ថុរបស់និយោជកដែលរកបាន ៣៦០ ដុល្លារអាមេរិកក្នុងមួយខែ។

គម្រោងការធានារបស់រដ្ឋាភិបាល ដើម្បីជួយដល់សហគ្រាសធុនតូច និងមធ្យមក្រោម Syarikat Jaminan Pembiayaan Perniagaan Berhad (SJPP) ត្រូវបានផ្តល់មូលនិធិបន្ថែមចំនួន ២.៤ ប៊ីលានដុល្លារអាមេរិកនៅក្នុងមូលនិធិ។ នេះរួមបញ្ចូលទាំង ៤៨០ លានដុល្លារអាមេរិក សម្រាប់អាជីវកម្មដែលគ្រប់គ្រងដោយ 'Bumiputera's' (ជនជាតិម៉ាឡេ)។ SJPP គឺជាអង្គភាពរដ្ឋាភិបាលដែលទទួលខុសត្រូវក្នុងការគ្រប់គ្រង និងគ្រប់គ្រងគម្រោងការធានារបស់រដ្ឋាភិបាល។ លើសពីនេះគម្រោងនេះមានសម្រាប់សហគ្រាសធុនតូច និងមធ្យមនៅគ្រប់វិស័យដែលមានភាគហ៊ុនយ៉ាងហោចណាស់ ៥១% នៃភាគហ៊ុនរបស់ពួកគេដែលគ្រប់គ្រងដោយជនជាតិម៉ាឡេស៊ី។*ដោយ វត្ថា វង្សវឌ្ឍនៈ*

*ប្រភព៖ _ThailandBusinessNews ចុះថ្ងៃទី០៩ខែវិច្ឆិកា ឆ្នាំ២០២១*

## ធនាគារវៀតណាមកាត់បន្ថយអត្រាការប្រាក់ សម្រាប់អ្នកខ្ចីប្រាក់រងគ្រោះដោយសារកូវីដ-១៩




*ដោយ ខេមបូណ្ណមីស*

ធនាគារនៅវៀតណាមចំនួន១៦ បានកាត់បន្ថយអត្រាការប្រាក់ សម្រាប់អ្នកខ្ចីប្រាក់ ដែលរងផលប៉ះពាល់ដោយសារកូវីដ១៩ ចាប់តាំងពីពាក់កណ្តាលខែកក្កដា រហូតដល់ដំណាច់ខែកញ្ញាកន្លងទៅនេះ។ នេះគឺជាការប្តេជ្ញាចិត្តជួយដល់ពលរដ្ឋ និងអាជីវកម្មដែលជំពាក់លុយធនាគារ គ្មានលទ្ធភាពសង។

ធនាគារ កសិកម្ម និងអភិវឌ្ឍន៍ជនបទវៀតណាម គឺបានកាត់បន្ថយអត្រាការប្រាក់ ច្រើនជាងគេបំផុត គឺមានដល់ទៅជាង ២០០លានដុល្លារអាមេរិក។ បន្ទាប់ពីនេះគឺធនាគារVietcombank បានកាត់បន្ថយជាង ៨៦ លានដុល្លារ និងធនាគារ BIDV បានកាត់បន្ថយជាង ៨៣លានដុល្លារអាមេរិកដែរ។

ដើម្បីអនុវត្តតាមសេចក្តីសម្រេចរបស់រដ្ឋាភិបាលវៀតណាម សមាគមធនាគារវៀតណាម ដែលមានធនាគារពាណិជ្ជធំៗចំនួន១៦ជាសមាជិក បានប្រកាសយល់ព្រមកាត់បន្ថយអត្រាកម្ចីសម្រាប់សហគ្រាស ដែលរងផលប៉ះពាល់ដោយសារកូវីដ១៩ចាប់ពីថ្ងៃទី១៥ ខែកក្កដា រហូតដល់ចុងឆ្នាំ២០២១នេះ ដោយចំនួនសរុប

មានតម្លៃជាទឹកប្រាក់ប្រមាណជាង ៩០០លានដុល្លារអាមេរិក។

ក្នុងនោះដែរ ធនាគារវដ្តចំនួន៤របស់វៀតណាម បានប្តេជ្ញាចិត្តនឹងផ្តល់កញ្ចប់ថវិកាគាំទ្រសរុបប្រមាណ ជាង ១៧៥លានដុល្លារអាមេរិក ដើម្បីកាត់បន្ថយអត្រាការប្រាក់ និងបានកាត់បន្ថយថ្លៃសេវាកម្ម១០០%តែម្តង សម្រាប់អតិថិជនរបស់ធនាគារទាំងនេះ៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណូមីសចេញផ្សាយថ្ងៃទី០២ខែវិច្ឆិកា ឆ្នាំ២០២១។*

## សេដ្ឋកិច្ចសកល

## ធនាគារកណ្តាលនៃសហរដ្ឋអាមេរិក បានបង្ហាញរបាយការណ៍អំពីការព្រួយបារម្ភរបស់វិនិយោគិនចំពោះ អតិផរណាកម្រិតខ្ពស់ក្នុងពេលមាន ការរីករាលដាលនៃជំងឺកូវីដ-១៩




*ប្រភព៖ reuters, 2021 រូបភាព៖ Brendan McDermid*

ធនាគារកណ្តាលមានការព្រួយបារម្ភអំពីការកើនឡើងអតិផរណា និងគោលនយោបាយរូបិយវត្ថុដែលកាន់តែតឹងតែង ជាហេតុនាំឱ្យក្លាយជាកង្វល់សម្រាប់អ្នកចូលរួមក្នុងទីផ្សារ ក្នុងអំឡុងពេលមានការរាតត្បាតនៃជំងឺកូវីដ-១៩។

តាមរយៈរបាយការណ៍ចុងក្រោយរបស់ ធនាគារកណ្តាលស្តីពីស្ថិរភាពហិរញ្ញវត្ថុនិង របាយការណ៍ពាក់កណ្តាលឆ្នាំក៏បានបង្ហាញផងដែរពីការកើនឡើងនៃការប្រើប្រាស់កាក់ស្ថិរភាព និង "ភាគហ៊ុន meme" ដែលជាបញ្ហាដែលគួរយកចិត្តទុកដាក់ និងបង្កហានិភ័យដែលអាចកើតមានចំពោះប្រព័ន្ធហិរញ្ញវត្ថុថ្មី។ យោងតាមការស្ទង់មតិ របស់ធនាគារកណ្តាលបានបញ្ជាក់ថា ប្រហែល ៧០% នៃអ្នកចូលរួមក្នុងទីផ្សារ បានលើកទង់បង្ហាញពីអតិផរណា និងគោលនយោបាយរបស់ ធនាគារកណ្តាល កាន់តែតឹងរ៉ឹង ដែលជាកង្វល់ខ្លាំងបំផុតរបស់ពួកគេក្នុងរយៈពេល ១២ទៅ ១៨ ខែខាងមុខ មុនពេលដែលអាចធន់នឹងថ្នាំបង្ការ ជំងឺកូវីដ-១៩ និងការបង្ក្រាបបទប្បញ្ញត្តិរបស់ចិនដែលមានសក្តានុពល។

ធនាគារកណ្តាលកំពុងតស៊ូជាមួយនឹងហានិភ័យអតិផរណាដោយផ្ទាល់នៅពេលដែល អត្រាការប្រាក់អាចនឹងត្រូវកើនឡើងហើយនៅពេលនេះអ្នកវិនិយោគរំពឹងថា ធនាគារកណ្តាលនឹងត្រូវបានបង្ខំឱ្យធ្វើសកម្មភាពឆាប់ៗជាងអ្នកបង្កើតគោលនយោបាយ។ ការផ្តោតអារម្មណ៍លើអតិផរណាបង្ហាញពីការត្រឡប់មកវិញក្នុងការព្រួយបារម្ភបន្ថែមទៀតនៅពេលដែលជំងឺរាតត្បាតកាន់តែធូរស្រាលនិង ហានិភ័យផ្នែកហិរញ្ញវត្ថុយ៉ាងទូលំទូលាយ។ ធនាគារកណ្តាល បានរកឃើញថា ភាពងាយរងគ្រោះនៅក្នុងអាជីវកម្ម និងគ្រួសារជាទូទៅធ្លាក់ចុះ ដោយសារផ្នែកខ្លះនៃអត្រាការប្រាក់ទាប និងកម្មវិធីគាំទ្ររបស់រដ្ឋាភិបាល។ តម្លៃផ្ទះបានកើនឡើងយ៉ាងទូលំទូលាយ ប៉ុន្តែមានសញ្ញាតិចតួចនៃការធ្លាក់ចុះនៅក្នុងស្តង់ដារការជានាទិញលក់ ។ ខណៈពេលដែលគុណភាពឥណទានទាំងមូលនៃផលប័ត្រធនាគារមានភាពប្រសើរឡើងយ៉ាងទូលំទូលាយក្នុងរយៈពេលប្រាំមួយខែចុងក្រោយនេះ ធនាគារកណ្តាលបានកត់សម្គាល់អត្រាការយឺតយ៉ាវសម្រាប់អ្នកខ្ចីទិញអចលនទ្រព្យ ពាណិជ្ជកម្ម និងឧស្សាហកម្មផ្សេងទៀតដែលរងផលប៉ះពាល់ដោយជំងឺរាតត្បាតនៅតែកើនឡើង។ ដោយឡែក អានុភាពនៅតែខ្ពស់សម្រាប់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត និងមូល

និធិការពារហានិភ័យ។ ទន្ទឹមនឹងនេះធនាគារកណ្ដាលបានកំណត់ពីការព្រួយបារម្ភ ដែលបណ្ដាលមកពីភាពមិនច្បាស់លាស់លើដំណើរនៃជំងឺរាតត្បាត កម្រិតនៃការគាំទ្ររបស់រដ្ឋាភិបាល និងការងើបឡើងវិញនៃសេដ្ឋកិច្ច។ *ដោយ សេន ចន្នី*

*ប្រភព៖reuters.ចេញផ្សាយថ្ងៃទី០៩ខែវិច្ឆិកា ឆ្នាំ២០២១*

## តម្លៃប្រេងធ្លាក់ចុះបន្ទាប់ពីការកើនឡើង តម្រូវការសម្រាប់ទស្សនវិស័យសេដ្ឋកិច្ចពិភពលោក



*ប្រភព៖ reuters, 2021 រូបភាព៖ Aaron Sheldrick*

តម្លៃប្រេងបានធ្លាក់ចុះ បន្ទាប់ពីការកើនឡើងពីរលើកជាប់ៗគ្នា ខណៈដែលការអនុម័តចំណាយហេដ្ឋារចនាសម្ព័ន្ធរបស់សហរដ្ឋអាមេរិក ការនាំចេញរបស់ចិន និងការស្ទុះងើបឡើងវិញក្រោយជំងឺរាតត្បាតសកលបានធ្វើឱ្យទស្សនវិស័យសម្រាប់តម្រូវការប្រេងឥន្ធនៈ ប្រេងឆៅ Brent បានធ្លាក់ចុះ ១០ សេននៅត្រឹម $៨៣,៣ ក្នុងមួយបារ៉ែល បន្ទាប់ពីបានកើនឡើង ០,៨% កាលពីសប្ដាហ៍មុន។ ប្រេងរបស់សហរដ្ឋអាមេរិកបានធ្លាក់ចុះ ៦ សេននៅត្រឹម $៨១,៨ក្នុងមួយបារ៉ែល បន្ទាប់ពីការកើនឡើង ០,៨% កាលពីថ្ងៃមុន។

អ្នកវិភាគទីផ្សារប្រេងជាន់ខ្ពស់ Rystad Energy លោក Louise Dickson បាននិយាយថា តើសេដ្ឋកិច្ចអាចសម្រេចបាននូវកំណើនចំពេល បរិយាកាសតម្លៃខ្ពស់នាពេលបច្ចុប្បន្ន ឬមានសក្ដានុពលនៅក្នុងសេណារីយ៉ូតម្លៃកាន់តែខ្ពស់ឬយ៉ាងណា?

អ្នកវិភាគទំនិញរបស់ JPMorgan Chase បាននិយាយថា តម្រូវការប្រេងពិភពលោកក្នុងខែវិច្ឆិកាគឺជិតត្រលប់ទៅកម្រិតមុនការរាតត្បាតដែលតម្រូវការ ១០០ លានបារ៉ែលក្នុងមួយថ្ងៃ (bpd) ។ កំណើននៃការប្រើប្រាស់កាន់តែច្រើននៅពេលដែលការធ្វើដំណើរចាប់ផ្ដើមឡើងវិញ ហើយតម្រូវការប្រេងឥន្ធនៈកើនឡើងផងដែរ។ ស្របពេលជាមួយគ្នានេះដែរ,ដោយសារអ្នកផលិតប្រេងធំៗបានរក្សាវិន័យផ្គត់ផ្គង់យ៉ាងតឹងរឹងក្នុងខែតុលា ធ្វើឱ្យតម្លៃប្រេងបានកើនឡើងដល់កម្រិតខ្ពស់ក្នុងរយៈពេលប្រាំពីរឆ្នាំ ដោយតម្លៃប្រេងឥន្ធនៈក៏កើនឡើងផងដែរ។ រដ្ឋមន្ត្រីនៃក្រសួងថាមពល Jennifer Granholm បានមានប្រសាសន៍ថា ទោះបីជាយ៉ាងណាក៏ដោយ លោកប្រធានាធិបតី Biden អាចនឹងចាត់វិធានការនៅដើមសប្ដាហ៍នេះ ដើម្បីដោះស្រាយការឡើងថ្លៃប្រេងសាំង។ យោងតាមការស្ទង់មតិរបស់ Reuters បានបង្ហាញថា ទោះបីជាទីផ្សារកាន់តែតឹងតែងក៏ដោយ ស្តុកប្រេងឆៅរបស់សហរដ្ឋអាមេរិកត្រូវបានគេរំពឹងថានឹងកើនឡើងក្នុងសប្ដាហ៍ទី៣អាចជួយកាត់បន្ថយការកើនឡើងបន្ថែមទៀត។ *ដោយ សេន ចន្នី*

*ប្រភព៖reuters.ចេញផ្សាយថ្ងៃទី០៩ខែវិច្ឆិកា ឆ្នាំ២០២១*

## មូលហេតុ តម្លៃស្បៀងអាហារសកលបន្តហក់ឡើងខ្ពស់៣ខែជាប់ៗគ្នានៅឆ្នាំនេះ




*ដោយ ខេមបូណ្ណមីស (ក្នុងផ្សារទំនើបមួយកន្លែងនៃប្រទេសកាណាដា)*

តម្លៃស្បៀងអាហារពិភពលោកនៅតែបន្តឡើងថ្លៃខ្លាំងក្នុង១ទសវត្សរ៍ចុងក្រោយ។ នៅក្នុងអំឡុងពេលមួយឆ្នាំចុងក្រោយនេះ តម្លៃស្បៀងអាហារបានឡើងជាង ៣១% ពិសេសបីខែចុងក្រោយគឺខែសីហា និងតុលា។ កំណើននេះ ជិតស្មើកម្រិតខ្ពស់បំផុត នាខែកុម្ភៈឆ្នាំ ២០១១ ដែលកាលនោះពិភពលោកជួបនឹងវិបត្តិស្បៀងអាហារសកល។

កត្តាដែលជំរុញឱ្យស្បៀងអាហារសកលលោកឡើងថ្លៃ គឺបណ្តាលមកពីការប្រមូលទិន្នផលគ្រាប់ធញ្ញជាតិបានចុះថយខ្លាំង នៅតាមប្រទេសដាំធញ្ញជាតិសំខាន់ៗដូចជាប្រទេសកាណាដា រុស្ស៊ី និង សហរដ្ឋអាមេរិកជាដើម។ តម្លៃប្រេងឆា ដែលចម្រាញ់ពីគ្រាប់ធញ្ញជាតិ ក៏បានឡើងថ្លៃដូចគ្នាដែរ ពោលគឺឡើងថ្លៃចំនួនជិត១០% ដែលជាតម្លៃខ្ពស់បំផុតមិនធ្លាប់មាន រីឯទំនិញធ្វើពីទឹកដោះគោ ក៏បានឡើងថ្លៃ។ ចំពោះសាច់សត្វ បានចុះថ្លៃប្រមាណជា០,៧% ចំនួន៣ខែជាប់គ្នាហើយ ប៉ុន្តែថ្លៃនៅតែខ្ពស់ បើធៀបនឹងថ្លៃឆ្នាំមុន( តម្លៃសាច់ជ្រូកបានធ្លាក់ចុះ ដោយសារតម្រូវការក្នុងប្រទេសចិន ធ្លាក់ចុះ )។ អង្គការ FAO មិនរំពឹងថា តម្លៃស្បៀងអាហារពិភពលោក ធ្លាក់ចុះមកវិញភ្លាមៗនោះទេ ព្រោះរដូវរងារនៅក្នុងប្រទេសជាច្រើនទូទាំងពិភពលោកកំពុងខិតចូលមកដល់ ជំរុញតម្រូវការស្បៀងអាហារកាន់តែច្រើន។

*ដោយ ម៉ែន ខេមរៈ*

*ប្រភព៖ខេមបូណូមីស ចេញផ្សាយថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០២១។*

## ជប៉ុនគ្រោងចែកប្រាក់ ៨៨០ដុល្លារ ឱ្យពលរដ្ឋចាប់ពីអាយុ១៨ឆ្នាំចុះ ដើម្បីជំរុញកំណើនសេដ្ឋកិច្ច



*ដោយ ខេមបូណូមីស*

រាជរដ្ឋាភិបាលរបស់នាយករដ្ឋមន្ត្រីជប៉ុនថ្មី មានផែនការផ្តល់សាច់ប្រាក់ឧបត្ថម្ភ ឬជាកូប៉ុង ដែលមានតម្លៃសរុបប្រមាណ៨៨០ដុល្លារអាមេរិក ទៅឱ្យប្រជាពលរដ្ឋរបស់ខ្លួនដែលមានអាយុ ១៨ឆ្នាំ ឬក្មេងជាងនេះ ដើម្បីបង្កើនការចំណាយពលរដ្ឋ សំដៅជំរុញដល់កំណើនសេដ្ឋកិច្ច។ តាមការគ្រោងទុករបស់រដ្ឋាភិបាល កញ្ចប់ថវិកានេះនឹងត្រូវចាប់ផ្តើមចែកជូនពលរដ្ឋនៅអំឡុងខែមីនាដល់ខែឧសភាឆ្នាំ២០២២។ ក្មេងៗទាំងអស់ អាចទទួលបានសាច់ប្រាក់ពីរដ្ឋផ្តល់ជូន ដោយមិនចាំបាច់គិតអំពីប្រាក់ចំណូលរបស់អាណាព្យាបាលរបស់ពួកគេឡើយ ប៉ុន្តែសម្រាប់ក្មេងដែលមានអាណាព្យាបាលមានប្រាក់ចំណូលខ្ពស់ ឬមានទ្រព្យច្រើននោះ គឺមិនមានសិទ្ធិទទួលបានសាច់ប្រាក់ឧបត្ថម្ភពីរដ្ឋនោះឡើយ។

ទោះយ៉ាងណា ក៏នៅមានការមន្ទិលសង្ស័យមួយចំនួនអំពីប្រសិទ្ធភាពនៃការផ្តល់សាច់ប្រាក់ឧបត្ថម្ភទាំងនេះក្នុងការជំរុញកំណើនសេដ្ឋកិច្ច ដ្បិតថា កាលពីខែមេសាឆ្នាំ២០២០កន្លងមកនេះ រាជរដ្ឋាភិបាលក៏ធ្លាប់បានផ្តល់សាច់ប្រាក់ក្នុងចំនួនប្រហែលគ្នានេះ ទៅឱ្យប្រជាពលរដ្ឋដែរ ក៏ប៉ុន្តែបែរជាពួកគេយកទៅសន្សំទុក ដោយមិនបានចំណាយនោះឡើយ ដូច្នេះវាបានជំរុញតិចតួចប៉ុណ្ណោះ នៅក្នុងចរន្តសេដ្ឋកិច្ច។ *ដោយ ម៉ែន ខេមរៈ*

*ប្រភព៖ខេមបូណូមីសចេញផ្សាយថ្ងៃទី០៨ខែវិច្ឆិកា ឆ្នាំ២០២១។*

## ការនាំចេញរបស់ចិននៅតែរក្សាភាពធន់ទោះ ស្ថិតក្នុងវិបត្តិខ្វះខាតថាមពល



*ដោយ ខេមបូណ្ឌមីស(រូបតំណាង ៖ ការនាំចេញរបស់ចិន)*

ការនាំចេញរបស់ចិន នៅបន្តរក្សាបានសញ្ញាវិជ្ជមាន ទោះស្ថិតក្នុងវិបត្តិខ្វះខាតថាមពល និងវិបត្តិកូវីដ១៩ ដែលកំពុងកម្រើកឡើងវិញយ៉ាងណាក្តី។ ក្នុងខែតុលាកន្លងទៅ ការនាំចេញរបស់ចិន មានទំហំទឹកប្រាក់សរុបជាង ៣០០ពាន់លានដុល្លារអាមេរិក កើន២៧% បើធៀបនឹងខែតុលាឆ្នាំ២០២០។ រីឯការនាំចូលមកវិញ មានទឹកប្រាក់ជាង ២១៥ពាន់លានដុល្លារ កើនជិត ២១%។ ការនាំចេញ និងនាំចូលនេះ មានកំរិតខ្ពស់ជាងកាលពីឆ្នាំមុន។

យ៉ាងណាក៏ដោយគឺនៅតែមានក្តីបារម្ភថា សេដ្ឋកិច្ចចិនជារួមនឹងមានការធ្លាក់ចុះ ឬអាចមានកំណើនយឺតជាងការរំពឹងទុក ទោះទំហំពាណិជ្ជកម្មរក្សាបានភាពធន់យ៉ាងណាក្តី។ ជាក់ស្តែង ក្នុងត្រីមាសទី៣ឆ្នាំ២០២១ មានកំណើនសេដ្ឋកិច្ចតែ ៤,៩%ប៉ុណ្ណោះ ធ្លាក់ចុះពី ៧,៩%កាលពីត្រីមាសទី២។

អតិរេកពាណិជ្ជកម្មរបស់ចិនសរុប ក្នុងខែតុលាមានជាង ៨៤ពាន់លានដុល្លារ កើនឡើងពីជាង៦៦ពាន់លានដុល្លារកាលពីខែកញ្ញា។ ដោយឡែក បើគេមើលលើអតិរេកពាណិជ្ជកម្មជាមួយសហរដ្ឋអាមេរិកវិញ ឃើញថាមានការថយចុះបន្តិចប៉ុណ្ណោះ ពី៤២ពាន់លានដុល្លារក្នុងខែកញ្ញា មកនៅត្រឹម៤០ពាន់លានដុល្លារក្នុងខែតុលា។ ការនេះបានបង្ហាញថា ទោះបីជាប្រទេសទាំងពីរនៅតែស្ថិតក្នុងជម្លោះពាណិជ្ជកម្ម ដែលបន្សល់តាំងពីប្រធានាធិបតីមុន ប៉ុន្តែមិនអាចធ្វើពាណិជ្ជកម្មដោយខ្វះគ្នាបានឡើយ ៕*ដោយ ម៉ែន ខែមរៈ ប្រភព៖ខេមបូណ្ឌមីសចេញផ្សាយថ្ងៃទី០៩ខែវិច្ឆិកា ឆ្នាំ២០២១។*

## នៅខែតុលាចិននាំចូលប្រេងឆៅធ្លាក់ចុះទាបបំផុតមិនធ្លាប់មានក្នុងរយៈពេល៣ឆ្នាំចុងក្រោយនេះ



*ដោយ ខេមបូណ្ឌមីស(រូបតំណាង: ក្រុមហ៊ុនចម្រាញ់ប្រេងធំៗរបស់រដ្ឋចិន)*

ការនាំចូលប្រេងឆៅរបស់ចិន នៅក្នុងខែតុលាបានធ្លាក់ចុះទាបបំផុត ដោយសារតម្លៃប្រេងហក់ឡើងខ្ពស់ពេក រួមនឹងក្រុមហ៊ុនដែលចម្រាញ់ប្រេងផ្សេងទៀត ត្រូវបានកំណត់កូតានាំចូលដោយរដ្ឋ។

ប្រទេសចិន គឺជាប្រទេសនាំចូលប្រេងឆៅធំជាងគេបំផុតក្នុងពិភពលោក ដោយកាលពីខែតុលាកន្លងទៅនេះ ការនាំចូលប្រេងបានធ្លាក់ចុះជិត១លានបារ៉ែលក្នុងមួយថ្ងៃធៀបនឹងខែកញ្ញា។ បើគិតរយៈពេល ១០ខែនៅឆ្នាំ២០២១ ប្រទេសចិនបាននាំចូលប្រេងមានការធ្លាក់ចុះជាង៧%ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។

ការនាំចូលប្រេងឆៅរបស់ចិន មានការធ្លាក់ចុះរៀងរាល់ខែ ហើយការធ្លាក់ចុះនេះ នៅចំពេលដែល តម្លៃប្រេងឆៅពិភពលោកបានហក់ឡើងខ្ពស់ដល់ទៅ៦២%នៅឆ្នាំនេះ ក៏ព្រោះតែសេដ្ឋកិច្ចនៅប្រទេសជាច្រើនទូទាំងពិភពលោក បានបើកដំណើរការឡើងវិញជាបណ្តើរៗ ដែលបានជំរុញតម្រូវការលើប្រេងឥន្ធនៈកើនឡើងខ្លាំង

។ ទាក់ទងនឹងចំនួនកូតាក៏ជាកត្តាមួយធ្វើឱ្យមានការកម្រិតលើការបញ្ហាទិញប្រេងពៅពីក្រៅប្រទេសផងដែរ គឺដើម្បីបង្ក្រាបលើការជួញដូរប្រេងខុសច្បាប់។

ការនាំចូលប្រេងរបស់ចិនត្រូវបានគេរំពឹងថា នឹងអាចងើបឡើងវិញនៅក្នុងខែវិច្ឆិកានេះ ដោយសារតែក្រុមហ៊ុនចម្រាញ់ប្រេងបានសន្យាថា នឹងដោះស្រាយបញ្ហាកង្វះខាតនៃការផ្គត់ផ្គង់ប្រេងម៉ាស៊ូត និងប្រេងសាំងដែលកំពុងជំរុញឱ្យតម្លៃប្រេងឥន្ទនៈនៅចិនកើនឡើងកាន់តែខ្លាំងថែមទៀត។

គិតមកទល់ថ្ងៃទី០៧ ខែវិច្ឆិកាតម្លៃប្រេងពៅពិភពលោកហាក់មានការថមថយចុះជាងមុនបន្តិចហើយ ប៉ុន្តែវានៅតែជាតម្លៃមួយខ្ពស់ដដែល ដូចជានៅទីផ្សារអាមេរិកតម្លៃប្រេងពៅមួយបារ៉ែលតម្លៃជាង ៨១ដុល្លារអាមេរិក រីឯនៅអង់គ្លេសវិញតម្លៃជិត៨៣ដុល្លារអាមេរិក៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណ្ឌមីសចេញផ្សាយថ្ងៃទី០៨ខែវិច្ឆិកាឆ្នាំ២០២១។*

## **ទិន្នន័យស្រាវជ្រាវសម្រាប់សប្តាហ៍បន្ទាប់**

ថ្ងៃចន្ទ ទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១

- សេដ្ឋកិច្ចជប៉ុនបានកើនឡើង 0.5% នៅត្រីមាសក្នុងរយៈពេល 3 ខែដល់ខែមិថុនា ឆ្នាំ 2021
- ភាពអត់ការងារធ្វើនៅទីក្រុង របស់ប្រទេសចិនបានធ្លាក់ចុះ នៅក្នុងខែកញ្ញា ឆ្នាំ 2021

ថ្ងៃអង្គារ ទី១៦ ខែវិច្ឆិកា ឆ្នាំ២០២១

- អត្រានីកម្មភាពរបស់ចក្រភពអង់គ្លេស បានធ្លាក់ចុះបន្ថែម ក្នុងរយៈពេលបីខែដល់ខែសីហា ឆ្នាំ 2021
- អត្រាអតិផរណាប្រចាំឆ្នាំនៅប្រទេសបារាំងត្រូវបានគេរំពឹងថានឹងកើនឡើងដល់ 2.6% ក្នុងខែតុលា ឆ្នាំ 2021

ថ្ងៃពុធ ទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១

- ប្រទេសជប៉ុនបានប្រកាសឱនភាពពាណិជ្ជកម្មក្នុងខែកញ្ញា ឆ្នាំ 2021
- កំណើន អត្រាអតិផរណាប្រចាំឆ្នាំនៅក្នុងតំបន់អឺរ៉ូ ក្នុងខែតុលា ឆ្នាំ 2021

ថ្ងៃព្រហស្បតិ៍ ទី១៨ ខែវិច្ឆិកា ឆ្នាំ២០២១

- កំណើននៃការវិនិយោគភាគហ៊ុនរបស់ជនបរទេសនៅក្នុងប្រទេសជប៉ុន ក្នុងសប្តាហ៍ដែលបញ្ចប់នៅថ្ងៃទី 30 ខែតុលា ឆ្នាំ 2021
- អត្រានីកម្មភាព នៅប្រទេសបារាំងបានធ្លាក់ចុះនៅក្នុងត្រីមាសទីពីរនៃឆ្នាំ 2021

ថ្ងៃសុក្រ ទី១៩ ខែវិច្ឆិកា ឆ្នាំ២០២១

- ការលក់រាយនៅក្នុងប្រទេសកាណាដាទំនងជាធ្លាក់ចុះ 1.9% ក្នុងរយៈពេលមួយខែមុនក្នុងខែកញ្ញា ឆ្នាំ 2021
- កំណើន បំណុលរដ្ឋាភិបាលប្រទេសទួរគីបានកើនឡើងដល់ 2 181 100 TRY លាននៅក្នុងខែកញ្ញាពី 2 041 700 TRY លាននៅក្នុងខែសីហាឆ្នាំ 2021៕